# សំឡេងរបស់យើងដើម្បីសមភាពយេនឌ័រ
## សេចក្តីថ្លែងការណ៍រួម

រាជធានីភ្នំពេញ ថ្ងៃទី៨ ខែមីនា ឆ្នាំ២០១៩

## ក្នុងទិវានារីអន្តរជាតិឆ្នាំ២០១៩ អង្គការសង្គមស៊ីវិលសូមអំពាវនាវឲ្យរាជរដ្ឋាភិបាលកម្ពុជាដោះស្រាយទៅលើការរំលោភសិទ្ធិស្ត្រីជាប្រព័ន្ធ

**ថ្ងៃទី៨ ខែមីនា ឆ្នាំ២០១៩ រាជធានីភ្នំពេញ៖** ក្នុងឱកាសទិវាសិទ្ធិនារីអន្តរជាតិឆ្នាំ២០១៩ យើងខ្ញុំជាអង្គការសង្គមស៊ីវិលដែលមានឈ្មោះខាងក្រោមសូមអំពាវនាវឲ្យរាជរដ្ឋាភិបាលកម្ពុជាចាត់វិធានការដើម្បីដោះស្រាយបញ្ហាប្រឈមសំខាន់ៗរបស់ស្ត្រីនៅក្នុងប្រទេសកម្ពុជាដូចខាងក្រោម៖

១. ភាពមានកម្រិតនៃចំនួនថវិកាថ្នាក់មូលដ្ឋាន និងថ្នាក់ជាតិឆ្លើយតបទៅនឹងការដោះស្រាយបញ្ហាយេនឌ័រ

២. ការរឹតត្បិតសិទ្ធិរបស់អ្នកការពារសិទ្ធិមនុស្សជាស្ត្រី និង

៣. សិទ្ធិទទួលបានយុត្តិធម៌នៅមានកម្រិត ជាពិសេសករណីអំពើហិង្សាក្នុងគ្រួសារ។

យើងខ្ញុំសូមកោតសរសើររាជរដ្ឋាភិបាលកម្ពុជាដែលបានបញ្ចូលអង្គការសង្គមស៊ីវិលជាច្រើនក្នុងកិច្ចប្រជុំពិគ្រោះយោបល់លើកដំបូងដើម្បីបង្កើតផែនការសកម្មភាពថ្មីស្តីពីអំពើហិង្សាលើស្ត្រី និងកុមារី ព្រមទាំងបានបង្ហាញពីការយកចិត្តទុកដាក់ទៅលើតម្រូវការរបស់ក្រុមងាយរងគ្រោះ រួមមានអ្នកស្រលាញ់ភេទដូចគ្នាជាស្ត្រីក្នុងការបង្កើតគោលនយោបាយយេនឌ័រឆ្នាំ២០១៩។ ទោះបីជាយ៉ាងណាក៏ដោយ គោលនយោបាយកន្លងមកមិនបានកំណត់ចំនួនកញ្ចប់ថវិកាឲ្យបានច្បាស់លាស់ពីរាជរដ្ឋាភិបាលនោះទេ ដែលនេះចាំបាច់ឲ្យមានតួអង្គ មិនមែនជារដ្ឋដូចជា ភ្នាក់ងារអង្គការសហប្រជាជាតិ រដ្ឋាភិបាលបរទេស និងអង្គការសង្គមស៊ីវិលដទៃទៀត ក្នុងការជួយផ្តល់មូលនិធិសម្រាប់កម្មវិធី និងសេវាមូលដ្ឋាននានាជាងរដ្ឋាភិបាល។ ក្រសួងរបស់រាជរដ្ឋាភិបាលភាគច្រើនមិនបានប្រមូលទិន្នន័យទាក់ទងនឹងយេនឌ័រ ហើយក៏មិនបានតាមដានការរីកចម្រើនលើបញ្ហាយេនឌ័រផងដែរ។ ហេតុដូចនេះបានជានៅមានភាពខ្វះខាតចំពោះទិន្នន័យសាធារណៈអំពីបញ្ហាវិសមភាពយេនឌ័រ។ យើងខ្ញុំសូមអំពាវនាវឲ្យរាជរដ្ឋាភិបាលកម្ពុជាកំណត់យកចំនួនថវិកាឲ្យបានច្បាស់លាស់នៅក្នុងកញ្ចប់ថវិកាជាតិដើម្បីធានាថាតួអង្គដែលជាអ្នកមានកាតព្វកិច្ចទាំងអស់អាចអនុវត្ត តាមដាន និងវាយតម្លៃគោលនយោបាយយេនឌ័រថ្មីនេះបាន។

# សំឡេងរបស់យើងដើម្បីសមភាពយេនឌ័រ
## សេចក្តីថ្លែងការណ៍រួម

រាជធានីភ្នំពេញ ថ្ងៃទី៨ ខែមីនា ឆ្នាំ២០១៩

អ្នកការពារសិទ្ធិមនុស្សជាស្ត្រីនៅក្នុងប្រទេសកម្ពុជាលើកកម្ពស់ និងការពារសិទ្ធិមនុស្សនៅក្នុងវិស័យផ្សេងៗគ្នាមានដូចជាសិទ្ធិទាក់ទងនឹងយេនឌ័រ សិទ្ធិក្នុងវិស័យបរិស្ថាន សិទ្ធិការងារ សិទ្ធិដីធ្លី សិទ្ធិជនជាតិដើមភាគតិច និងសិទ្ធិរបស់អ្នកស្រលាញ់ភេទដូចគ្នាជាដើម។ ពួកគាត់ប្រឈមនឹងអំពើហិង្សា និងការបៀតបៀនពីគ្រួសាររបស់គាត់ដែលក្នុងទម្រង់ជាអំពើហិង្សាក្នុងគ្រួសារ ក៏ដូចជាការប្រឈមនឹងការយាយីពីប្រព័ន្ធយុត្តិធម៌ រួមទាំងការឃុំខ្លួននៅក្នុងពន្ធនាគារដែលជារឿយៗបណ្តាលឲ្យមានផលវិបាកយ៉ាងធ្ងន់ធ្ងរ។ យើងខ្ញុំសូមជម្រុញឲ្យរាជរដ្ឋាភិបាលកម្ពុជាទទួលស្គាល់ និងបញ្ចូលតម្រូវការរបស់អ្នកការពារសិទ្ធិមនុស្សជាស្ត្រីនៅក្នុងផែនការសកម្មភាពថ្មីទាក់ទងនឹងសមភាពយេនឌ័រ និងការការពារអំពើហិង្សាប្រឆាំងនឹងស្ត្រី។

ជាមួយគ្នាផងដែរ យើងខ្ញុំចូលរួមសាទរចំពោះការប្តេជ្ញារបស់រាជរដ្ឋាភិបាលកម្ពុជាដើម្បីពិនិត្យមើលច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ("ច្បាប់ហិង្សាក្នុងគ្រួសារ")។ ស្ត្រីដែលរួចពីការរងគ្រោះដោយអំពើហិង្សាក្នុងគ្រួសារប្រឈមនឹងការរើសអើងនៅក្នុងប្រព័ន្ធយុត្តិធម៌ ដោយសារកង្វះស្ត្រីធ្វើការងារនៅក្នុងវិស័យយុត្តិធម៌ ផ្នត់គំនិតសង្គមលើបញ្ហាយេនឌ័រ កង្វះជំនួយផ្នែកច្បាប់ កង្វះទំនុកចិត្តលើប្រព័ន្ធតុលាការក្នុងស្រុកនិងការទទួលបានយុត្តិធម៌ ជាពិសេសស្ត្រីនៅតាមតំបន់ដាច់ស្រយាល។ អាជ្ញាធរតែងតែដាក់សម្ពាធលើស្ត្រីដើម្បីផ្សះផ្សាក្រៅផ្លូវការក្នុងការដោះស្រាយបញ្ហាអំពើហិង្សាក្នុងគ្រួសារ ខណៈពេលដែលច្បាប់ស្តីពីអំពើហិង្សាក្នុងគ្រួសារមិនបានគ្របដណ្តប់លើគ្រប់ទម្រង់នៃអំពើហិង្សាក្នុងគ្រួសារនៅមានភាពចន្លោះប្រហោង និងជម្រុញឲ្យមានការផ្សះផ្សាជាជាងការដាក់ទោសទណ្ឌ។ ជាលទ្ធផល មានសំណុំរឿងតិចតួចណាស់ដែលបានបញ្ជូនទៅតុលាការ និងអ្នកប្រព្រឹត្តិបទល្មើសកម្រទទួលបានការផ្តន្ទាទោសណាស់។ ដូច្នេះហើយយើងខ្ញុំសូមទទូចរាជរដ្ឋាភិបាលកម្ពុជាពិនិត្យ និងធ្វើវិសោធនកម្ម "ច្បាប់ហិង្សាក្នុងគ្រួសារ" ឡើងវិញដើម្បីការពារទម្លាប់នៃការផ្សះផ្សាក្រៅប្រព័ន្ធតុលាការ តាមសំណើរបស់គណៈកម្មាធិការអនុសញ្ញា "ស៊ីដ-ដ" និងផ្តល់វគ្គបណ្តុះបណ្តាលទៅដល់តួអង្គដែលមានកាតព្វកិច្ចទាំងអស់ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិអំពីវិធីសាស្ត្របញ្ជ្រាបការយល់ដឹងពីយេនឌ័រក្នុងការអន្តរាគមន៍ដោះស្រាយករណីអំពើហិង្សារក្នុងគ្រួសារ។

DCA actalliance | មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា Cambodian Center for Human Rights | មជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ CCIM cambodian center for independent media | NGO-CEDAW

# សំឡេងរបស់យើងដើម្បីសមភាពយេនឌ័រ

## សេចក្តីថ្លែងការណ៍រួម

រាជធានីភ្នំពេញ ថ្ងៃទី៨ ខែមីនា ឆ្នាំ២០១៩

យើងខ្ញុំសូមអំពាវនាវបន្ថែមទៅដល់រាជរដ្ឋាភិបាលកម្ពុជាឲ្យទទួលយក និងចាត់វិធានការដើម្បីអនុវត្តឲ្យបានពេញលេញទៅលើអនុសាសន៍ទាំងអស់ដែលរដ្ឋជាសមាជិកបានលើកឡើងនៅក្នុងកិច្ចប្រជុំវដ្តទី៣នៃការត្រួតពិនិត្យជាសាកលតាមពេលវេលាកំណត់ពាក់ព័ន្ធទៅនឹងស្ត្រី កុមារី អ្នកការពារសិទ្ធិមនុស្សជាស្ត្រី និងការរើសអើងដោយផ្អែកលើយេនឌ័រ។

---

**ព័ត៌មានបន្ថែម សូមទាក់ទង៖**

អ្នកស្រី ចក់ សុភាព នាយិកាប្រតិបត្តិ ម.ស.ម.ក អ៊ីម៉ែល៖ chaksopheap@cchrcambodia.org

ឬទូរសព្ទ៖ ៨៥៥ (០) ១១ ៩៤៣ ២១៣

លោក ដានីឡូ កាស្ពេ នាយកស្តីទី CCIM អ៊ីម៉ែល៖ dl.caspe@ccimcambodia.org

ឬទូរសព្ទ៖ ៨៥៥ (០) ៦០ ៥០០ ០៨០

លោកស្រី ជិន ចាន់នាង អគ្គលេខាធិការនៃ NGO-CEDAW អ៊ីម៉ែល៖ ngocedaw.pnh@gmail.com

ឬទូរសព្ទ៖ ៨៥៥ (០) ១២ ៦៦ ៨៨ ៥៣